# របាយការណ៍ប្រចាំខែមេសា ឆ្នាំ ២០១៦ របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ

នៅក្នុងខែមេសា ឆ្នាំ២០១៦ មន្ត្រីរាជការរបស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ បានបំពេញភារកិច្ចសម្រេចលទ្ធផលដូចខាងក្រោម÷

1. ស្ថានភាពមន្ត្រីរាជការ÷

ស្ថានភាពមន្ត្រីរាជការរបស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ មានមន្ត្រីក្របខណ្ឌ និងកិច្ចសន្យាសរុបចំនួន ៣១នាក់ ស្ត្រី ០៤ នាក់ ដឹកនាំដោយប្រធានមន្ទីរ ០១រូប និងអនុប្រធានមន្ទីរ ០២រូប ។

2. សកម្មភាពថ្នាក់ដឹកនាំមន្ទីរ÷

- ចូលរួមវេទិកាសាធារណៈចំនួន ០៤ដង
- ចូលរួមប្រជុំពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងកម្មវិធីវិនិយោគ ៣ឆ្នាំ រំកិល ថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៦ នៅសាលប្រជុំមន្ទីរផែនការខេត្តក្រចេះ
- ចូលរួមប្រជុំសម្រេចលើទិន្នន័យដីសហគមន៍ជនជាតិដើមភាគតិចភូមិប៉ាក្លែ និងភូមិរវៀង ថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៦ នៅសាលប្រជុំក្រុមប្រឹក្សាខេត្តក្រចេះ
- ចូលរួមសិក្ខាសាលាបណ្តុះបណ្តាលស្តីពីការជំរុញ និងកិច្ចសម្រួលការវិនិយោគ នៅថ្ងៃទី២៩-៣០ ខែមីនា ឆ្នាំ២០១៦ នៅទីរួមខេត្តមណ្ឌលគិរី
- ចូលរួមប្រជុំពិនិត្យ និងពិភាក្សាករណីសំណើសុំដីសម្បទានសង្គមកិច្ច នៅសាលប្រជុំក្រុមប្រឹក្សាខេត្តក្រចេះ ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦
- ចូលរួមប្រជុំជាមួយគណៈកម្មាការនាយកមូលនិធិសមធម៌ប្រចាំត្រីមាសទី១ ថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៦ នៅមន្ទីរពេទ្យបង្អែកឆ្លូង និងថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៦ នៅមន្ទីរសុខាភិបាលខេត្ត
- ចូលរួមសិក្ខាសាលាស្តីពី បច្ចេកវិទ្យាសម្រាប់កម្មវិធីផ្គត់ផ្គង់ទឹកស្អាត ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៦ នៅសាលប្រជុំធំទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ
- ចូលរួមសន្និបាតបូកសរុបលទ្ធផលការងាររបស់មន្ទីរសុខាភិបាលខេត្តក្រចេះ ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៦ នៅសាលប្រជុំមន្ទីរសុខាភិបាលខេត្តក្រចេះ
- ចូលរួមជាភ្ញៀវកិត្តិយសពិធីសម្ពោធបើកឱ្យប្រើប្រាស់នូវអគារសម្ភពនៃមន្ទីរពេទ្យបង្អែកខេត្ត ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៦ បរិវេណមន្ទីរពេទ្យខេត្តក្រចេះ
- ចូលរួមសិក្ខាសាលាស្តីពី សម្ពោធគម្រោងការការពារកុមារតាមសហគមន៍ នៅសណ្ឋាគារ ហ៊ារ ប៊ុន្នី ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦
- ចូលរួមប្រជុំគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសខេត្ត ដើម្បីពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងកម្មវិធីបីឆ្នាំរំកិលខេត្ត ២០១៦-២០១៨ នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៦ នៅសាលប្រជុំសាលាខេត្តក្រចេះ

- ចូលរួមវេទិកាសាធារណៈនៅស្រុកឆ្លូង ថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៦ នៅឃុំព្រែកសាម៉ាន់
- ចូលរួមវេទិកាសាធារណៈនៅស្រុកចិត្របុរី ថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៦ នៅឃុំថ្មអណ្ដើក
- ចូលរួមប្រជុំ គ.ក.ស.កខេត្ត ថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ នៅសាលប្រជុំក្រុមប្រឹក្សាខេត្ត
- ចូលរួមពិធីផ្ដល់អណ្ដូងទឹកតាមសាលារៀននៅឃុំសោប និងឃុំជ្រោយបន្ទាយ ថ្ងៃទី០៦-០៧ ខែមេសា ឆ្នាំ២០១៦
- ចូលរួមប្រជុំជាមួយក្រុមអាជ្ញាធរសវនកម្មជាតិស្ដីពីការចុះប្រមូលព័ត៌មាន ដើម្បីរៀបចំផែនការសវនកម្ម ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៦ សាលប្រជុំសាលាខេត្តក្រចេះ
- ចូលរួមប្រជុំប្រចាំត្រីមាសទី១ នៅសាលប្រជុំសាលាខេត្តក្រចេះ ថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៦ ។

3. <u>សកម្មភាពតាមការិយាល័យ</u>÷

**3.1. ការិយាល័យរដ្ឋបាល និងកិច្ចការទូទៅ**

ក. ផ្នែកការងារលិខិតចូល ÷ សរុបចំនួន ៤១លេខ ក្នុងនោះមាន :

- លិខិតចូលពីអង្គភាពនានាក្រៅមន្ទីរ ចំនួន ៣៤លេខ
- លិខិតក្រសួងសាមី និងអង្គភាពក្រោមឱវាទមន្ទីរ ចំនួន ០៧លេខ

ខ. ផ្នែកការងារលិខិតចេញ ÷ មានចំនួន ៧៤លេខ ក្នុងនោះមាន :

- លិខិតចេញទៅបណ្ដាអង្គភាពនានាក្រៅមន្ទីរ ចំនួន២៨ លេខ
- លិខិតចេញពាក់ព័ន្ធស្ថានភាពមន្ត្រីរាជការ ចំនួន៤២ លេខ
- លិខិតចេញទូទៅ លិខិតអញ្ជើញ និងសេចក្ដីជូនដំណឹង ចំនួន០១ លេខ
- លិខិតចេញទៅបណ្ដាអង្គភាពនានា និងក្រសួងសាមី ចំនួន០៣ លេខ

គ. ផ្នែកបញ្ជីវត្តមាន÷ ពិនិត្យការចុះបញ្ជីវត្តមានប្រចាំថ្ងៃ ។

3.2. **<u>ការិយាល័យផ្លូវជនបទ</u>**÷

**<u>សកម្មភាពការងារ</u>**

- ចុះស្រង់ទិន្នន័យផ្លូវប្រភេទទី៤ បានចំនួន០១ខ្សែ ប្រវែង ១៣ ៤០០ ម៉ែត្រស្ថិតនៅឃុំជ្រោយបន្ទាយ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ
- ចុះធ្វើបច្ចុប្បន្នភាពផ្លូវប្រភេទទី៣ បានចំនួន ០៣ខ្សែ ប្រវែង៤០ ៨០០ ម៉ែត្រ ស្ថិតនៅឃុំថ្មី និងឃុំដារ ស្រុកចិត្របុរីខេត្តក្រចេះ
- លោកប្រធានកម្មវិធី RIP-III នៅPMU និងតំណាងក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ និងអង្គភាពអនុវត្ត និងអង្គភាពអនុវត្តកម្មវិធី RIP III ខេត្ត ចុះពិនិត្យ និងវាយតម្លៃផ្លូវថែទាំលក្ខណៈខួប ៥0% ចំនួន ០៣ខ្សែ ប្រវែង ២០ ៨០០ ម៉ែត្រ ស្ថិតនៅឃុំព្រែកប្រសព្វ ឃុំកំពង់គរ និងឃុំតាម៉ៅ ស្រុកព្រែកប្រសព្វ

- បញ្ជាក់បច្ចេកទេសគម្រោងមូលនិធិឃុំ សង្កាត់ ស្រុក ឆ្នាំ២០១៦ របស់សាលាខេត្ត ទីចាត់ការផែនការវិនិយោគ បានចំនួន ០៣គម្រោង ។
- ចុះសិក្សាពិនិត្យ និងវាយតម្លៃស្ពានឈើទ្រុឌទ្រោម ០២កន្លែង ស្ថិតនៅឃុំកន្ធួត និងឃុំថ្មី ស្រុកចិត្របុរី
- តំណាងក្រុមការងារក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ និងក្រុមការងារលទ្ធកម្មខេត្ត ក្រុមការងារមន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ ចុះពិនិត្យនិងវាយតម្លៃ បញ្ចប់សុពលភាពការងារជួសជុលផ្លូវ ពីភូមិខ្សាត់ទៅស្ទឹងទ្រ ប្រវែង៦ ៨០០ ម៉ែត្រស្ថិតនៅឃុំតាម៉ៅស្រុកព្រែកប្រសព្វ ។

<u>លទ្ធផលការងារ</u>

- ការងារផ្លូវថែទាំលក្ខណៈខួប ចំនួន ០៣ខ្សែ ប្រវែង ២០ ៨០០ ម៉ែត្រ ស្ថិតនៅឃុំព្រែកប្រសព្វ ឃុំកំពង់គ ឃុំតាម៉ៅ ស្រុកព្រែកប្រសព្វ សម្រេចបាន ៩០%។

3.3. **ការិយាល័យផ្គត់ផ្គង់ទឹកជនបទ÷**

ចុះសិក្សាទីតាំងអណ្តូងស្នប់នៅភូមិល្អក់តាមសំណូមពររបស់ប្រជាពលរដ្ឋក្នុងវេទិកាសាធារណៈ ។

3.4. **<u>ការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ</u>÷** (គ្មានសកម្មភាព)

3.5. **<u>ការិយាល័យអភិវឌ្ឍន៍សហគមន៍</u>÷**

ចុះត្រួតពិនិត្យតាមដានសកម្មភាព និងធ្វើបច្ចុប្បន្នភាពសមាសភាព គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (គ.អ.ភ) ចំនួន ១៧ ភូមិ ក្នុងឃុំចំនួន ០២ គឺឃុំស្វាយជ្រះ និងឃុំឃ្សឹម ។

3.6. **<u>ការិយាល័យជនជាតិដើមភាគតិច</u>÷** (គ្មានសកម្មភាព)

3.7. **<u>ការិយាល័យថែទាំសុខភាពជនបទ</u>÷**

បំផុស និងជំរុញ ការសាងសង់បង្គន់អនាម័យតាមគ្រួសារបានចំនួន **៦០ បង្គន់** ក្នុងនោះ÷

- ឃុំព្រែកសាម៉ាន់ បានចំនួន **៤១ បង្គន់**
- ឃុំសណ្តាន់ បានចំនួន **០៩ បង្គន់**
- ឃុំកោះច្រែង បានចំនួន **០៤ បង្គន់**
- ឃុំថ្មី បានចំនួន **០៦ បង្គន់**

3.8. **<u>ការងារបណ្តុះបណ្តាលមន្ត្រីរាជការ</u>** ÷ មានចំនួន ០១ លើក ។

4. **<u>ទិសដៅបន្ត÷</u>**

- បន្តការជួសជុលផ្លូវថែទាំលក្ខណៈខួបចំនួន ០៣ខ្សែ ប្រវែង ២០ ៨០០ ម៉ែត្រ ស្ថិតនៅឃុំព្រែកប្រសព្វ ឃុំកំពង់គ ឃុំតាម៉ៅ ស្រុកព្រែកប្រសព្វ
- ជួសជុលផ្លូវថែទាំលក្ខណៈខួប ចំនួន ០១ខ្សែ ប្រវែង ១០ ០០០ម៉ែត្រ ស្ថិតនៅឃុំកញ្ជរ ស្រុកឆ្លូង
- បន្តចុះស្រង់ទិន្នន័យផ្លូវ និងធ្វើបច្ចុប្បន្នភាពផ្លូវ នៅស្រុកសចិត្របុរី ស្រុកសំបូរ និងស្រុកស្នួល
- ចុះជួសជុសអណ្តូងស្នប់ក្នុងស្រុកចិត្របុរី និងស្រុកសំបូរ

- តាមដានសកម្មភាព និងធ្វើបច្ចុប្បន្នភាព គ.អ.ភ ក្នុង៤ឃុំ គឺ ឃុំស្ទួល ឃុំស្រែចារ ឃុំ២ធ្នូ ក្នុងស្រុកស្ទួល និងឃុំកន្ទួត ក្នុងស្រុកចិត្របុរី
- បន្តជំរុញ និងបំផុសការសាងសង់បង្គន់តាមគ្រួសារ នៅស្រុកចិត្របុរី ស្រុកឆ្លូង ស្រុកសំបូរ ស្រុកព្រែកប្រសព្វ ។

**ប្រធានមន្ទីរ**